**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៣៧ សសរ

## សេចក្តីសំរេច

## ស្តីពីការបង្កើតឡើងនូវក្រុមការងារចំរុះមួយ រវាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជាមួយនឹង ក្រុមហ៊ុន Chevron Overseas Petroleum Limited ព្រមទាំងក្រុមហ៊ុនដៃគូ និងស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សារួមគ្នារៀបចំអោយមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការប្រើប្រាស់ ឧស្ម័នធម្មជាតិ ពីប្លុក A ដែនសមុទ្រកម្ពុជា

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការបង្កើត អាជ្ញាធរប្រេងកាតជាតិកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦ /០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី និង ជាប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា

### សំរេច

**ប្រការ ១ :** បង្កើតក្រុមការងារចំរុះមួយទទួលបន្ទុកអនុវត្តន៍កិច្ចព្រមព្រៀងសិក្សារួមគ្នា ដើម្បីរៀបចំអោយមានកាលានុវត្តន៍ភាពចំពោះការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការវិនិយោគឧស្ម័ន នៃឧស្ម័នធម្មជាតិនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម | **សុខ អាន**, ទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមការងារ និង អ្នកធានា ( Chairman and Sponsor ) | |
| ២-ឯកឧត្តម | សុខ ចិន្តា, តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៣-ឯកឧត្តម | ញឹក ច្រឹង, តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| ៤-ឯកឧត្តម | ទី នរិន្ទ, តំណាងអាជ្ញាធរអគ្គិសនីកម្ពុជា | សមាជិក |
| ៥-ឯកឧត្តម | តែ ដួង តារា, តំណាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា | សមាជិក |
| ៦-ឯកឧត្តម | សយ សុខា, តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧-លោក | យឹម ណុលសុន, តំណាងអគ្គិសនីកម្ពុជា | សមាជិក |
| ៨-លោក | វ៉ាន់ ហុង, មន្ត្រីអាជ្ញាធរប្រេងកាតជាតិកម្ពុជា | លេខាធិការក្រុមការងារ |

**ប្រការ ២ :** ក្រុមការងារចំរុះនេះមានភារកិច្ច ធ្វើការជាមួយគ្នានឹងក្រុមការងារនៃក្រុមហ៊ុនរុករកប្រេងកាតអាមេរិកាំង **Chevron Overseas Petroleum Limited** ព្រមទាំងក្រុមហ៊ុនដៃគូ និងស្ថាប័នពាក់ព័ន្ធ ដើម្បី :

- រៀបចំផ្តល់អនុសាសន៍សេដ្ឋកិច្ចលំអិតមួយជូនរាជរដ្ឋាភិបាលស្តីពី វិធី មធ្យោបាយ និងជំរើស ដែលទាក់ទងដល់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការប្រើប្រាស់ឧស្ម័នធម្មជាតិពីប្លុក A ដែនសមុទ្រកម្ពុជា បំរើអោយរោងចក្រ អគ្គិសនី និង អាជីវកម្ម ឧស្សាហកម្មដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- រៀបចំផែនការជំហានដំបូង សំរាប់ការអនុវត្តន៍ នៃគ្រប់គំរោងការថាមពលទាំងអស់ ដែលនឹងប្រើប្រាស់ឧស្ម័នធម្មជាតិជាវត្ថុធាតុដើម និងគ្រប់គំរោងការងារហេដ្ឋារចនាសម្ព័ន្ធនានាដែលពាក់ព័ន្ធ ។
- ធ្វើការពិនិត្យដោយហ្មត់ចត់សារឡើងវិញនូវបទដ្ឋាន បទបញ្ញត្តិ ក្របខ័ណ្ឌច្បាប់ ដោយសំរបសំរួលជាមួយអ្វីដែលមាននៅនឹងកន្លែង និងតំរូវថ្មីចាំបាច់ ដើម្បីគ្រប់គ្រង និងជំរុញលើកទឹកចិត្តដល់ការវិនិយោគទុន និងអាជីវកម្មកិតអាប់ស្រ្តឹម មីតស្រ្តឹម និង ដោនស្រ្តឹមគាំទ្រដល់ការប្រើប្រាស់ឧស្ម័នធម្មជាតិ ។
- ផ្តល់អនុសាសន៍លើការកំណត់ដាក់ចេញ នូវសេចក្តីសំរេច អាជ្ញាប័ណ្ណផ្លូវការ (រួមបញ្ចូលទាំងអាជ្ញាប័ណ្ណបរិស្ថានផង) និងការយល់ព្រមដែលតំរូវចាំបាច់អោយមាន ក្នុងការអនុវត្តន៍ចំពោះគ្រប់គំរោងការថាមពលទាំងឡាយ ហើយនិងបង្ហាញជូននាកាលវេលាសមស្របនូវបណ្តាបញ្ហាដែលអាចកើតមានឡើង ក្នុងការអនុវត្តន៍គំរោង និងដំណោះស្រាយចំពោះបញ្ហាទាំងនោះផង ។
- ធ្វើរបាយការណ៍អំពីលទ្ធផល នៃការសិក្សារួមគ្នា ជូនរាជរដ្ឋាភិបាលទៅតាមជំហានការងារនីមួយៗ ។

**ប្រការ ៣ :** ប្រធានក្រុមការងារមានសិទ្ធិជ្រើសតាំងបន្ថែមនូវសមាជិកក្រុមការងារថ្មី ទៅតាមតំរូវការចាំបាច់ ។ ក្នុងពេលកោះប្រជុំការងារ ប្រធានក្រុមការងារមានសិទ្ធិ អញ្ជើញចូលរួមក្រុមការងារក្រុមហ៊ុន Chevron Overseas Petroleum ( Cambodia ) Limited និងតំណាងក្រុមហ៊ុនដៃគូរក្នុងគំរោងការងារ និងតំណាងក្រុមហ៊ុនរដ្ឋ ឯកជនដទៃទៀត ដែលពាក់ព័ន្ធក្នុងការសិក្សារួមគ្នានេះ ។

**ប្រការ ៤ :** សមាជិកក្រុមការងារត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងពេលអវត្តមានប្រធានក្រុមការងារ នាយក្រុមការងារទទួលចាត់ចែងការងារជំនួស និងធ្វើរបាយការណ៍ពីលទ្ធផលការងារ ជូនប្រធានក្រុមការងារ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ប្រធាន និង សមាជិកនៃក្រុមការងារដែលមានរាយនាមក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចំលងជូន</u> :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ឧទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់

-ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-គ្រប់ក្រសួង ស្ថាប័នកណ្តាល

-គ្រប់សាលាខេត្ត ក្រុង

-ឯកសារ កាលប្បវត្តិ